STATE OF CALIFORNIA
HEALTH AND HUMAN SERVICES AGENCY
CALIFORNIA DEPARTMENT OF SOCIAL SERVICES

# សេចក្តីប្រកាសបង់សងប័ណ្ណទិញម្ហូប សំរាប់តែកំហុសដែលបណ្តាល មកពីក្រសួង ប្រកាសចុងក្រោយ

នៃខណ្ឌ

កាលបរិច្ឆេទសេចក្តីប្រកាស : ______
សំណុំរឿង
ឈ្មោះ : ______
លេខ ______
អ្នកកាន់សំណុំរឿង
ឈ្មោះ : ______
លេខ : ______
ទូរស័ព្ទ : ______
អាសយដ្ឋាន : ______

(ADDRESSEE)

មានសំណួរឬ? សូមសួរអ្នកកាន់សំណុំរឿងរបស់លោកអ្នក ។

**សេចក្តីបំភ្លឺពីរដ្ឋ** : បើលោកអ្នកគិតថាសេចក្តីសំរេចនេះខុស លោកអ្នកអាចស្នើសុំសេចក្តីបំភ្លឺពីរដ្ឋ លើកលែងតែលោកអ្នកបានមានសេចក្តីបំភ្លឺរួចហើយលើចំនួនដែលលោកអ្នកជំពាក់ ។ នៅខាងខ្នងនៃសេចក្តីប្រកាសនេះមានប្រាប់អំពីរបៀប ។ ជំនួយរបស់លោកអ្នកអាចមិនបានផ្លាស់ប្តូរ បើសិនជាលោកអ្នកស្នើសុំសេចក្តីបំភ្លឺ នៅមុនពេលសេចក្តីសំរេចនេះអនុវត្ត ។

ក្រសួងសុខមាលភាពនៃខណ្ឌបានធ្វើកំហុសមួយ ។
យើងបានជំរាបលោកអ្នកពីមុនថា លោកអ្នកត្រូវបង់សងប័ណ្ណទិញម្ហូប (Food Stamps) ដែលត្រូវបានផ្តល់លើសចំនួនទៅឱ្យ :

☐ លោកអ្នក ។
☐ មនុស្សដែលលោកអ្នកធានាឈ្មោះ______________________________ ។

លោកអ្នកនៅជំពាក់ $ ______________________ ។

**បំរាម** : បើសិនជាលោកអ្នកជឿថាការផ្តល់ប័ណ្ណទិញម្ហូបឱ្យលើសនេះខុស នេះគឺជាឱកាសចុងក្រោយរបស់លោកអ្នកដើម្បីស្នើសុំសេចក្តីបំភ្លឺ ។ ខាងក្រោយនៃទំព័រនេះមានជំរាបអំពីរបៀប ។ បើសិនជាលោកអ្នកទទួលប័ណ្ណទិញម្ហូប ខណ្ឌអាចទាមទារចំនួនប័ណ្ណទិញម្ហូបលើសដោយបន្ថយជំនួយប័ណ្ណទិញម្ហូបរបស់លោកអ្នក ។ បើសិនជាលោកអ្នកឈប់ទទួលជំនួយប័ណ្ណទិញម្ហូបនៅមុនពេលប័ណ្ណទិញម្ហូបដែលទទួលលើសសងរួច ខណ្ឌអាចដកយកចំនួនដែលលោកអ្នកជំពាក់ពីប្រាក់ពន្ធដាររដ្ឋ/សហព័ន្ធលើប្រាក់ចំណូលដែលសងមកឱ្យវិញរបស់លោកអ្នក ។

☐ **លោកអ្នកមិនបានយល់ព្រមសង :**

- លោកអ្នកអាចបង់សងទាំងអស់ ឬ
- លោកអ្នកអាចសងប័ណ្ណទិញម្ហូបដែលទទួលលើស តាមលក្ខខណ្ឌទាំងឡាយដែលលោកអ្នកយល់ព្រមតាមក្នុងសំណៅព្រមព្រៀងសង (Repayment Agreement ឬ DFA 377.7F1) ដែលបានដាក់ភ្ជាប់ទៅជាមួយនេះ ។
  - — បំពេញ ចុះហត្ថលេខា ហើយផ្តល់សំណៅព្រមព្រៀងសងដែលផ្ញើទៅជាមួយនេះមកវិញ ។
  - — ការព្រមព្រៀងសងរបស់លោកអ្នក នឹងយោងទៅតាមលទ្ធភាពអាចបង់សងក្នុងពេលបច្ចុប្បន្នរបស់លោកអ្នក ដូចបានគណនាដោយខណ្ឌ ។ ការផ្លាស់ប្តូរណាមួយលើលទ្ធភាពអាចបង់សងរបស់លោកអ្នក អាចផ្លាស់ប្តូរប្រាក់បង់សងប្រចាំខែរបស់លោកអ្នក ។
- លោកអ្នកមិនចាំបាច់ប្រើប្រាក់ជំនួយមនុស្សចាស់៦៥ឆ្នាំឬលើស ខ្វាក់ ឬពិការ (SSI) ដែលលោកអ្នកបានទទួលដើម្បីបង់សងជំនួយទទួលលើសចំនួននេះទេ ។
- បើលោកអ្នកមិនព្រមបង់សង ខណ្ឌអាចប្រើវិធីដទៃទៀតដើម្បីទាមទារចំនួនដែលជំពាក់នោះដូចជាការទាមទារតាមរយៈតុលាការជាដើម ។
- បើខណ្ឌប្តឹងទាមទារចំនួនដែលលោកអ្នកបានជំពាក់នោះ លោកអ្នកក៏អាចតម្រូវឱ្យចេញថ្លៃឈ្នួលតុលាការផងដែរ ។
- បើលោកអ្នកមិនសងចំនួនដែលបានជំពាក់នោះទេ ខណ្ឌនឹងកាត់យកប្រាក់ពន្ធដារលើប្រាក់ចំណូលនៃរដ្ឋដែលសងឱយលោកអ្នកវិញ (State Income Tax Refund) និង/ឬសុំឱយតុលាការកាត់ប្រាក់ខែរបស់លោកអ្នក ឬទ្រព្យសម្បត្តិណាមួយដែលលោកអ្នកមាន ។

☐ **លោកអ្នកមិនបានសងដូចដែលបានយល់ព្រម :**

- លោកអ្នកត្រូវប្រាប់យើង នៅពេលណាដែលលោកអ្នកមិនអាចបង់សងបានដូចដែលបានយល់ព្រមពីមុនមក ។ លោកអ្នកត្រូវពន្យល់ថាហេតុអ្វីបានជាលោកអ្នកមិនអាចសងបាន ។ លោកអ្នកអាចស្នើសុំឱយខណ្ឌគិតរកគំរោងការសងថ្មីមួយទៀត ។
  - — បំពេញ ចុះហត្ថលេខា ហើយផ្តល់សំណៅព្រមព្រៀងសង (Repayment Agreement ឬ DFA 377.7E1) ដែលផ្ញើទៅជាមួយនេះមកវិញ ។
  - ☐ បើលោកអ្នកកំពុងទទួលជំនួយប័ណ្ណទិញម្ហូប ហើយលោកអ្នកមិនបានផ្តល់សំណៅព្រមព្រៀងសងថ្មីមកវិញនៅក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃសេចក្តីប្រកាសនេះ ជំនួយប័ណ្ណទិញម្ហូបក្នុងក្រុមគ្រួសារលោកអ្នកនឹងបន្ថយទៅចំនួន $____________ ចាប់ផ្តើមពី_____________ ។
- បើលោកអ្នកមិនព្រមសងដូចដែលបានយល់ព្រម ហើយលោកអ្នកមិនបានទទួលកិច្ចព្រមព្រៀងសងថ្មីមួយទៀតទេ ខណ្ឌអាចសុំឱយលោកអ្នកបង់សងចំនួនជំពាក់ទាំងអស់នោះនៅក្នុងពេលឥឡូវនេះ ។
- បើលោកអ្នកមិនព្រមបង់សងដូចបានព្រមព្រៀង ខណ្ឌនឹងប្រើវិធីដទៃទៀតដើម្បីទាមទារចំនួនដែលបានជំពាក់នោះ ដូចជាការទាមទារតាមរយៈតុលាការជាដើម ។
- បើខណ្ឌបានប្តឹងទាមទារចំនួនដែលលោកអ្នកជំពាក់ លោកអ្នកក៏អាចតម្រូវឱយបង់ថ្លៃឈ្នួលតុលាការផងដែរ ។
- បើលោកអ្នកមិនសងចំនួនដែលលោកអ្នកបានជំពាក់ ខណ្ឌអាចកាត់យកប្រាក់ពន្ធដារលើប្រាក់ចំណូលនៃរដ្ឋដែលសងឱយវិញរបស់លោកអ្នក និង/ឬសុំឱយតុលាការកាត់ប្រាក់ខែ ឬទ្រព្យសម្បត្តិណាមួយដែលលោកអ្នកមាន ។

**ច្បាប់** : ច្បាប់ទាំងនេះបានអនុវត្ត ។ លោកអ្នកអាចពិនិត្យច្បាប់ទាំងនេះសាឡើងវិញ នៅឯការិយាល័យសុខុមាលភាព (Welfare office) របស់លោកអ្នក : MS 63-801.22, 63-801.43, 63-801.7 ។